# របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន

## ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

## សម្រាប់ត្រីមាស និង រយៈពេល ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩

របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន ដែលភ្ជាប់មកជាមួយ គឺជាការប្រែសំរួលជាភាសាខ្មែរ ពីរបាយការណ៍ជាភាសាអង់គ្លេស។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ ឯកសារអង់គ្លេសត្រូវបានយកជាគោល។

# មាតិកា


| | |
|---|---|
| របាយការណ៍នៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ៣ |
| របាយការណ៍ចំណូលពេញលេញសង្ខេបបណ្តោះអាសន្ន | ៤ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបបណ្តោះអាសន្ន | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបបណ្តោះអាសន្ន | ៧ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ននានា | ៨ |

Grant Thornton

# របាយការណ៍នៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន

**ហ្គ្រេនថន (ខេមបូឌា) លីមីតធីត**
ជាន់ទី២០ អាគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
កែងមហាវិថីព្រះមុនីវង្ស
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

## ជូនចំពោះភាគហ៊ុននិករបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវ របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ននាកាលបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបបណ្តោះអាសន្នសម្រាប់ត្រីមាស និងរយៈពេល៦ខែចុងការិយបរិច្ឆេទ និងសេចក្តីសង្ខេបកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ៣៤ *"ស្តីពីរបាយការណ៍ហិរញ្ញវត្ថុសង្ខេប"*។ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺ ធ្វើការសន្និដ្ឋានទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដោយផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាមរបាយការណ៍ទាក់ទងនឹងស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី "ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុបណ្តោះអាសន្ន ដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន"។ ការត្រួតពិនិត្យលើរបាយការណ៍សង្ខេបហិរញ្ញវត្ថុបណ្តោះអាសន្នរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការអនុវត្តនូវ ការវិភាគ និងនិតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថា បានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងត្រូវកត់សម្គាល់ ក្នុងការធ្វើសវនកម្ម។ ដូច្នេះ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះទេ។

## សេចក្តីសន្និដ្ឋាន

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំ ជឿជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នរបស់ក្រុមហ៊ុនដែលបានភ្ជាប់មកជាមួយនេះ មិនបានបង្ហាញអោយបានត្រឹមត្រូវ ប្រកបដោយសារវន្តភាព និងសមស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជាលេខ ៣៤ ស្តីពី *"របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន"* នោះទេ។

Grant Thornton

ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩

គណនេយ្យករជំនាញនិងសវនករប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និង សមាជិកគឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន

| | កំណត់សម្គាល់ | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | ៨ | **១៤.៨៣១.៧១១** | **៦០.៣៩៤.៧២៧** | ១៣.៦២៥.៧៦៥ | ៥៥.១១៦.២១៩ |
| ទ្រព្យសកម្មអរូបិយ | ៩ | **១០.១៩៧** | **៤១.៥២២** | ១២.៧៩៤ | ៥១.៧៥២ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **១៤.៨៤១.៩០៨** | **៦០.៤៣៦.២៤៩** | ១៣.៦៣៨.៥៥៩ | ៥៥.១៦៧.៩៧១ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ១០ | **២៦.៧៥៦.៣៩៧** | **១០៨.៩៥២.០៤៩** | ២៥.៤៤៩.៨៦៨ | ១០២.៩៤៤.៧១៦ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ១១ | **៥០.៥៥៥.១៤០** | **២០៥.៨៦០.៥៣០** | ៤៨.៨២៩.៦៦១ | ១៩៧.៥១៥.៩៧៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១២ | **៦៥៤.៨៦០** | **២.៦៦៦.៥៩០** | ១.០៣២.៨៦៣ | ៤.១៧៧.៩៣១ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **៧៧.៩៦៦.៣៩៧** | **៣១៧.៤៧៩.១៦៩** | ៧៥.៣១២.៣៩២ | ៣០៤.៦៣៨.៦២៦ |
| **ទ្រព្យសកម្មសរុប** | | **៩២.៨០៨.៣០៥** | **៣៧៧.៩១៥.៤១៨** | ៨៨.៩៥០.៩៥១ | ៣៥៩.៨០៦.៥៩៧ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៣ | **១០.០០០.០០០** | **៤០.៧២០.០០០** | ១០.០០០.០០០ | ៤០.៤៥០.០០០ |
| បុព្វលាភភាគហ៊ុន | ១៤ | **១៧.២៨០.០០០** | **៧០.៣៦៤.១៦០** | ១៧.២៨០.០០០ | ៦៩.៨៩៧.៦០០ |
| ចំណេញរក្សាទុក | | **៤១.៥០៩.៩២១** | **១៦៩.០២៨.៣៩៨** | ៤១.១៣២.០២៩ | ១៦៦.៣៧៩.០៥៧ |
| **មូលធនសរុប** | | **៦៨.៧៨៩.៩២១** | **២៨០.១១២.៥៥៨** | ៦៨.៤១២.០២៩ | ២៧៦.៧២៦.៦៥៧ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| បំណុលពន្ធពន្យារ | | **៤២៧.៦៤១** | **១.៧៤១.៣៥៣** | ៤២៧.៦៤១ | ១.៧២៩.៨០៨ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៥ | **១.៣៥០.០០០** | **៥.៤៩៧.២០០** | ១.៥៣០.០០០ | ៦.១៨៨.៨៥០ |
| **បំណុលរយៈពេលវែងសរុប** | | **១.៧៧៧.៦៤១** | **៧.២៣៨.៥៥៣** | ១.៩៥៧.៦៤១ | ៧.៩១៨.៦៥៨ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៥ | **១២.៩៥៤.១១៣** | **៥២.៧៤៩.១៥០** | ១១.២០៥.៧៩៥ | ៤៥.៣២៧.៤៤១ |
| ប្រាក់កម្ចី | ១៦ | **៨.៨៦៧.៥៦០** | **៣៦.១០៨.៧០៤** | ៧.០១៦.៩២៧ | ២៨.៣៨៣.៤៧០ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | | **៤១៩.០៧០** | **១.៧០៦.៤៥៣** | ៣៥៨.៥៥៩ | ១.៤៥០.៣៧១ |
| **បំណុលរយៈពេលខ្លីសរុប** | | **២២.២៤០.៧៤៣** | **៩០.៥៦៤.៣០៧** | ១៨.៥៨១.២៨១ | ៧៥.១៦១.២៨២ |
| **បំណុលសរុប** | | **២៤.០១៨.៣៨៤** | **៩៧.៨០២.៨៦០** | ២០.៥៣៨.៩២២ | ៨៣.០៧៩.៩៤០ |
| **មូលធន និងបំណុលសរុប** | | **៩២.៨០៨.៣០៥** | **៣៧៧.៩១៥.៤១៨** | ៨៨.៩៥០.៩៥១ | ៣៥៩.៨០៦.៥៩៧ |

# របាយការណ៍ចំណូលពេញលេញសង្ខេបបណ្តោះអាសន្ន

| | កំណត់សម្គាល់ | **បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៣ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៣ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណូល | ១៧ | **៤៣.៥៣២.៨៨៧** | **១៧៧.២៦៥.៩១៦** | ២៣.៧៧៣.៩៤៩ | ៩៦.៦៦៤.៨៧៧ |
| ថ្លៃដើម | ១៨ | **(៤១.០៨០.៧០១)** | **(១៦៧.២៨០.៦១៤)** | (២៣.១៩០.១២៥) | (៩៤.២៩១.០៤៨) |
| **ចំណេញដុល** | | **២.៤៥២.១៨៦** | **៩.៩៨៥.៣០២** | ៥៨៣.៨២៤ | ២.៣៧៣.៨២៩ |
| ចំណូលផ្សេងៗ | ១៩ | **២.៨៦៨** | **១១.៦៧៨** | ២៥.៦២៤ | ១០៤.១៨៧ |
| ចំណាយរដ្ឋបាល | ២០ | **(១.១០០.៩១៩)** | **(៤.៤៨២.៩៤២)** | (៩៣០.៧៧៨) | (៣.៧៨៤.៥៤៣) |
| ចំណាយលើការដឹកជញ្ជូន | ២១ | **(៩៧០.៥១០)** | **(៣.៩៥១.៩១៧)** | (៤៥៦.៥៦៩) | (១.៨៥៦.៤១០) |
| ចំណាយផ្សេងៗ | | **(៣៥.៦១៥)** | **(១៤៥.០២៤)** | (១៦.៧៦៧) | (៦៨.១៧៥) |
| **ចំណេញ(ខាត)ប្រតិបត្តិការ** | | **៣៤៨.០១០** | **១.៤១៧.០៩៧** | (៧៩៤.៦៦៦) | (៣.២៣១.១១២) |
| ចំណូលហិរញ្ញប្បទាន | | **៤៨៥** | **១.៩៧៥** | ៤០៦ | ១.៦៥១ |
| ចំណាយហិរញ្ញប្បទាន | ២២ | **(៩១.៥៩៥)** | **(៣៧២.៩៧៥)** | (៧២.៨៨៣) | (២៩៦.៣៤២) |
| **ចំណេញ(ខាត)មុនបង់ពន្ធ** | | **២៥៦.៩០០** | **១.០៤៦.០៩៧** | (៨៦៧.១៤៣) | (៣.៥២៥.៨០៣) |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៣ | **(៥១.៣៨០)** | **(២០៩.២១៩)** | - | - |
| **ចំណេញ(ខាត)ក្នុងការិយបរិច្ឆេទ** | | **២០៥.៥២០** | **៨៣៦.៨៧៨** | (៨៦៧.១៤៣) | (៣.៥២៥.៨០៣) |
| ចំណូលលម្អិតផ្សេងៗសង្ខេប | | - | - | - | - |
| **ចំណូល(ខាត)លម្អិតផ្សេងៗសរុប** | | **២០៥.៥២០** | **៨៣៦.៨៧៨** | (៨៦៧.១៤៣) | (៣.៥២៥.៨០៣) |

ប្រាក់ចំណេញក្នុង១ភាគហ៊ុន ដែលអាចបែងចែកទៅភាគហ៊ុននិករបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | កំណត់សម្គាល់ | **បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៣ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៣ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណេញ(ខាត)គោលក្នុងមួយភាគហ៊ុន | ២៤ | **0.00៥** | **0.0២១** | (0.0២២) | (0.0៨៨) |
| ចំណេញ(ខាត)ថយចុះក្នុងមួយភាគហ៊ុន | ២៤ | **0.00៥** | **0.0២១** | (0.0២២) | (0.0៨៨) |

# របាយការណ៍ចំណូលពេញលេញសង្ខេបបណ្តោះអាសន្ន

| | កំណត់សម្គាល់ | **បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណូល | ១៧ | **៨០.៣១៣.៣៧៩** | **៣២៧.០៣៦.០៧៩** | ៤៧.០៥២.៥៤៨ | ១៩១.៣១៥.៦៦០ |
| ថ្លៃដើម | ១៨ | **(៧៥.០៣១.៥៩៥)** | **(៣០៥.៥២៨.៦៥៥)** | (៤៣.៨១៣.១៩១) | (១៧៨.១៤៤.៤៣៥) |
| **ចំណេញដុល** | | **៥.២៨១.៧៨៤** | **២១.៥០៧.៤២៤** | ៣.២៣៩.៣៥៧ | ១៣.១៧១.២២៥ |
| ចំណូលផ្សេងៗ | ១៩ | **១៨.៣៤៤** | **៧៤.៦៩៧** | ៤១.៦៧០ | ១៦៩.៤៣០ |
| ចំណាយរដ្ឋបាល | ២០ | **(២.១៨០.១៧៥)** | **(៨.៨៧៧.៦៧៣)** | (១.៨៨៨.៣១៥) | (៧.៦៧៧.៨៨៩) |
| ចំណាយលើការដឹកជញ្ជូន | ២១ | **(២.៤១៤.៩៣១)** | **(៩.៨៣៣.៥៩៩)** | (៨០១.៣៦២) | (៣.២៥៨.៣៣៨) |
| ចំណាយផ្សេងៗ | | **(៤៥.៣៣១)** | **(១៨៤.៥៨៨)** | (៦៥.៩៤៤) | (២៦៨.១២៨) |
| **ចំណេញប្រតិបត្តិការ** | | **៦៥៩.៦៩១** | **២.៦៨៦.២៦១** | ៥២៥.៤០៦ | ២.១៣៦.៣០០ |
| ចំណូលហិរញ្ញប្បទាន | | **៨២៨** | **៣.៣៧២** | ៧០៧ | ២.៨៧៥ |
| ចំណាយហិរញ្ញប្បទាន | ២២ | **(១៨៨.១៥៤)** | **(៧៦៦.១៦៣)** | (១៣៦.៤០៥) | (៥៥៤.៦២៣) |
| **ចំណេញមុនបង់ពន្ធ** | | **៤៧២.៣៦៥** | **១.៩២៣.៤៧០** | ៣៨៩.៧០៨ | ១.៥៨៤.៥៥២ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៣ | **(៩៤.៤៧៣)** | **(៣៨៤.៦៩៤)** | (៧៧.៩៤២) | (៣១៦.៩១២) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **៣៧៧.៨៩២** | **១.៥៣៨.៧៧៦** | ៣១១.៧៦៦ | ១.២៦៧.៦៤០ |
| ចំណូលលម្អិតផ្សេងៗសង្ខេប | | - | - | - | - |
| **ចំណូលលម្អិតផ្សេងៗសរុប** | | **៣៧៧.៨៩២** | **១.៥៣៨.៧៧៦** | ៣១១.៧៦៦ | ១.២៦៧.៦៤០ |

ប្រាក់ចំណេញក្នុង១ភាគហ៊ុន ដែលអាចបែងចែកទៅភាគហ៊ុននិករបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | កំណត់សម្គាល់ | **បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណេញគោលក្នុងមួយភាគហ៊ុន | ២៤ | **០.០០៩** | **០.០៣៨** | ០.០០៨ | ០.០៣២ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន | ២៤ | **០.០០៩** | **០.០៣៨** | ០.០០៨ | ០.០៣២ |

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបបណ្តោះអាសន្ន

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម** | | | | | |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ (បានធ្វើសវនកម្ម)** | ១៣ | ១០.០០០.០០០ | ១៧.២៨០.០០០ | ៤១.១៣២.០២៩ | ៦៨.៤១២.០២៩ |
| ចំណេញសម្រាប់រយៈពេល៦ខែ | | - | - | ៣៧៧.៨៩២ | ៣៧៧.៨៩២ |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ (ដុល្លារអាមេរិក)** | | ១០.០០០.០០០ | ១៧.២៨០.០០០ | ៤១.៥០៩.៩២១ | ៦៨.៧៨៩.៩២១ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់រៀល (កំណត់សម្គាល់៤)** | | ៤០.៧២០.០០០ | ៧០.៣៦៤.១៦០ | ១៦៩.០២៨.៣៩៨ | ២៨០.១១២.៥៥៨ |
| មិនបានធ្វើសវនកម្ម | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ (បានធ្វើសវនកម្ម) | ១៣ | ១០.០០០.០០០ | ១៧.២៨០.០០០ | ៤០.៣០០.៧០៧ | ៦៧.៥៨០.៧០៧ |
| ចំណេញសម្រាប់រយៈពេល៦ខែ | | - | - | ៣១១.៧៦៦ | ៣១១.៧៦៦ |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ (ដុល្លារអាមេរិក) | | ១០.០០០.០០០ | ១៧.២៨០.០០០ | ៤០.៦១២.៤៧៣ | ៦៧.៨៩២.៤៧៣ |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់រៀល (កំណត់សម្គាល់៤) | | ៤០.៦៦០.០០០ | ៧០.២៦០.៤៨០ | ១៦៥.១៣០.៣១៥ | ២៧៦.០៥០.៧៩៥ |

# របាយការណ៍លំហូរសាច់ប្រាក់សង្ខេបបណ្តោះអាសន្ន

| | កំណត់សម្គាល់ | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធ | | **៤៧២.៣៦៥** | **១.៩២៣.៤៧០** | ៣៨៩.៧០៨ | ១.៥៨៤.៥៥២ |
| **និយ័តកម្ម៖** | | | | | |
| រំលស់ទ្រព្យសកម្មអរូបិយ | ៩ | **២.៥៩៧** | **១០.៥៧៥** | ៤.៧៣៩ | ១៩.២៦៩ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៨ | **៨៥៩.២៤៤** | **៣.៤៩៨.៨៤២** | ៧៣៦.២៩១ | ២.៩៩៣.៧៥៩ |
| ចំណាយការប្រាក់ | ២២ | **១៨៨.១៥៤** | **៧៦៦.១៦៣** | ១៣៦.៤០៥ | ៥៥៤.៦២៣ |
| ចំណូលការប្រាក់ | | **(៨២៨)** | **(៣.៣៧២)** | (៧០៧) | (២.៨៧៥) |
| **ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល** | | **១.៥២១.៥៣២** | **៦.១៩៥.៦៧៨** | ១.២៦៦.៤៣៦ | ៥.១៤៩.៣២៨ |
| **បម្រែបម្រួលដើមទុនបង្វិល៖** | | | | | |
| បម្រែបម្រួលសន្និធិ | ១០ | **(១.៣០៦.៥២៩)** | **(៥.៣២០.១៨៦)** | (៦.៩៣៣.៩៦៩) | (២៨.១៩៣.៥១៨) |
| បម្រែបម្រួលគណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ១១ | **៧៧១.៩០៤** | **៣.១៤៣.១៩២** | ១.៣៤៥.៧៧៣ | ៥.៤៧១.៩១២ |
| បម្រែបម្រួលគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៥ | **១.២២៣.២០៨** | **៤.៩៨០.៩០៣** | ១៤៨.៦៨៩ | ៦០៤.៥៦៩ |
| **សាច់ប្រាក់បានមកពី(ប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | **២.២១០.១១៥** | **៨.៩៩៩.៥៨៧** | (៤.១៧៣.០៧១) | (១៦.៩៦៧.៧០៩) |
| ពន្ធលើប្រាក់ចំណូលបានបង់រួច | | **(៣៣.៩៦២)** | **(១៣៨.២៩៣)** | (៦៣៧.៤៦៤) | (២.៥៩១.៩២៩) |
| **សាច់ប្រាក់សុទ្ធបានមកពី(ប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | **២.១៧៦.១៥៣** | **៨.៨៦១.២៩៤** | (៤.៨១០.៥៣៥) | (១៩.៥៥៩.៦៣៧) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៨ | **(២.០៦៥.១៩០)** | **(៨.៤០៩.៤៥៤)** | (៣៩៥.៣៦៨) | (១.៦០៧.៥៦៦) |
| ការទិញទ្រព្យសកម្មអរូបិយ | ៩ | - | - | (៣.៧៣៦) | (១៥.១៩១) |
| ការប្រាក់ទទួលបាន | | **៨២៨** | **៣.៣៧២** | ៧០៧ | ២.៨៧៥ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(២.០៦៤.៣៦២)** | **(៨.៤០៦.០៨២)** | (៣៩៨.៣៩៧) | (១.៦១៩.៨៨២) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| (ការទូទាត់សងទៅ)/បុរេប្រទានពីក្រុមហ៊ុនសម្ព័ន្ធញ្ញាតិនានា | ១៥ | **(២.១៥២.២៧៣)** | **(៨.៧៦៤.០៥៦)** | ៥.៥៦០.០៥១ | ២២.៦០៧.១៦៧ |
| បុរេប្រទានទៅក្រុមហ៊ុនសម្ព័ន្ធញ្ញាតិនានា | ១១ | - | - | (៥១.២៨៦) | (២០៨.៥២៩) |
| ការប្រាក់បានបង់ | ២២ | **(១៨៨.១៥៤)** | **(៧៦៦.១៦៣)** | (១៣៦.៤០៥) | (៥៥៤.៦២៣) |
| ការទូទាត់សងកម្ចីធនាគារ | ១៦ | **(៥.៧០៩.៣៦៧)** | **(២៣.២៤៨.៥៤៣)** | (៤.១៧៨.៤៨៤) | (១៦.៩៨៩.៧១៦) |
| ប្រាក់កម្ចីពីធនាគារ | ១៦ | **៧.៥៦០.០០០** | **៣០.៧៨៤.៣២០** | ៤.០០០.០០០ | ១៦.២៦៤.០០០ |
| **សាច់ប្រាក់សុទ្ធ(ប្រើក្នុង)បានមកពីសកម្មភាពហិរញ្ញប្បទាន** | | **(៤៨៩.៧៩៤)** | **(១.៩៩៤.៤៤២)** | ៥.១៩៣.៨៧៦ | ២១.១១៨.២៩៩ |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **(៣៧៨.០០៣)** | **(១.៥៣៩.២៣០)** | (១៥.០៥៦) | (៦១.២២១) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ | | **១.០៣២.៨៦៣** | **៤.១៧៧.៩៣១** | ២២៨.៥៣៧ | ៩២៤.៤៣២ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | **២៧.៨៨៩** | - | ៤.៨០៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | **៦៥៤.៨៦០** | **២.៦៦៦.៥៩០** | ២១៣.៤៨១ | ៨៦៨.០១៤ |

ជូនភ្ជាប់កំណត់សម្គាល់ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ននានា

## ១ ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ប្រេ្គន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") បានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមហ៊ុនបានធ្វើវិសោធនកម្មទៅលើការចុះបញ្ជីពាណិជ្ជកម្ម ដើម្បីផ្លាស់ប្តូរទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ដូច្នេះ ក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។

ទីស្នាក់ការ និងទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនមេរបស់ក្រុមហ៊ុនគឺ ប្រេ្គន ធ្វីន អ៊ិនធើណេសិនណល អិលធីឌី ជាក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅ British Virgin Islands។

## ២ សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺកាត់ដេរសំលៀកបំពាក់។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

## ៣ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នត្រូវបានរៀបចំសម្រាប់ត្រីមាស និងរយៈពេល៦ខែ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ របាយការណ៍សង្ខេបនេះត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *"របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន"* ។ របាយការណ៍សង្ខេបនេះមិនបានបញ្ចូលរាល់ព័ត៌មានដែលតំរូវអោយមានក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ ដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ននេះ គួរតែត្រូវបានអានគួបផ្សំជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចនាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងកំណត់សម្គាល់ សម្រាប់របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន។

## ៤ រូបិយប័ណ្ណគោល និង រូបិយប័ណ្ណបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល។ ដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យគោលជាប្រាក់ដុល្លារអាមេរិក ថ្នាក់គ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណគោល និងបង្ហាញរបស់ក្រុមហ៊ុន ដើម្បីឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានបកប្រែទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃធ្វើប្រតិបត្តិការនោះ។ ទ្រព្យសកម្ម ឬបំណុលរូបិយវត្ថុនាកាលបរិច្ឆេទ ដែលរូបិយប័ណ្ណកំណត់របស់វាក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានបកប្រែទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នាកាលបរិច្ឆេទនោះ។

ភាពខុសគ្នាដែលបានកើតឡើងពីការបកប្រែរូបិយប័ណ្ណ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលពេញលេញ។

ការបកប្រែចំនួនទឹកប្រាក់ពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ គឺដើម្បីតែអនុវត្តតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ តែប៉ុណ្ណោះ និងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមជាផ្លូវការ ១ដុល្លារ ស្មើនឹង ៤.០៧២រៀល នាកាលបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨: ៤.០៤៥រៀល និង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨: ៤.០៦៦រៀល)។ ការបកប្រែនេះ មិនបានធ្វើសវនកម្ម និងមិនគួរត្រូវបានបកស្រាយជាការតំណាងថាចំនួនទឹកប្រាក់ដុល្លារអាមេរិកត្រូវបាន ឬអាចត្រូវបាន ឬក៏អាចនៅថ្ងៃអនាគត ប្តូរជាខ្មែររៀល ក្នុងអត្រានេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀត។

## ៥ គោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យ និងវិធីសាស្ត្រនៃការគណនាដែលបានអនុវត្ត គឺស្របទៅនឹងគោលការណ៍ និងវិធីសាស្ត្រដែលបានអនុវត្ត ទៅលើរបាយការណ៍ហិរញ្ញវត្ថុនាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលបានធ្វើសវនកម្មរួចហើយ។

## ៦ បម្រែបម្រួលតាមរដូវកាល ឬវដ្តនៃប្រតិបត្តិការអាជីវកម្ម

តម្រូវការផលិតផលរបស់ក្រុមហ៊ុន គឺងាយនឹងប្រែប្រួលទៅតាមរដូវកាល។

## ៧ ការប៉ាន់ស្មាន

កំឡុងពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតមួយចំនួនអំពីការទទួលស្គាល់ និងការវាស់វែងនៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។ លទ្ធផលជាក់ស្តែង អាចនឹងមានការខុសប្លែកពីការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលកំណត់ដោយគណៈគ្រប់គ្រង និងលទ្ធផលនេះកម្រស្មើនឹងលទ្ធផលដែលបានប៉ាន់ស្មាន។

ការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដែលបូករួមទាំងប្រភពសំខាន់នៃភាពមិនច្បាស់លាស់របស់ការប៉ាន់ស្មាន ត្រូវបានគេអនុវត្តដូចគ្នាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយរបស់ ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ ករណីលើកលែងតែមួយគត់ គឺការប៉ាន់ស្មានលើបំណុលពន្ធលើប្រាក់ចំណូលដែលបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ត្រូវបានប្រើប្រាស់ការប៉ាន់ស្មានអត្រាពន្ធលើប្រាក់ចំណូលដែលមានប្រសិទ្ធភាពប្រចាំឆ្នាំ គុណនឹងប្រាក់ចំណេញមុនបង់ពន្ធក្នុងអំឡុងពេលបណ្តោះអាសន្ននេះ។

## ៨ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីភតិសន្យារយៈពេលវែង ដុល្លារអាមេរិក | សំណង់អាគារ ដុល្លារអាមេរិក | រោងចក្រ និងគ្រឿងយន្ត ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារ និងកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **មិនបានធ្វើសវនកម្ម** | | | | | | |
| **តម្លៃដុលក្នុងបញ្ជីគណនេយ្យសរុប** | | | | | | |
| សមតុល្យថ្ងៃទី១ខែមករា ឆ្នាំ២០១៩ | ៣.៨៨០.០០០ | ៨.៩៧១.៣១១ | ១៥.២៧៥.៨៧៣ | ១១៧.៤២០ | ១.៨២៨.៣៩៤ | ៣០.០៧២.៩៩៨ |
| ការទិញបន្ថែម | - | - | ២.០១៧.១៤៣ | - | ៤៨.០៤៧ | ២.០៦៥.១៩០ |
| សមតុល្យថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០១៩ | ៣.៨៨០.០០០ | ៨.៩៧១.៣១១ | ១៧.២៩៣.០១៦ | ១១៧.៤២០ | ១.៨៧៦.៤៤១ | ៣២.១៣៨.១៨៨ |
| | | | | | | |
| **រំលស់បង្គរ** | | | | | | |
| សមតុល្យថ្ងៃទី១ខែមករា ឆ្នាំ២០១៩ | (២៧១.៦០០) | (៤.៩៦៨.៣០៩) | (៩.៤២៣.៥១៥) | (១០៨.៨៤៨) | (១.៦៧៤.៩៦១) | (១៦.៤៤៧.២៣៣) |
| រំលស់ក្នុងគ្រា | (១៩.២០០) | (២២៤.២៨៣) | (៥៨៩.៧១៥) | (១.៦០២) | (២៤.៤៤៤) | (៨៥៩.២៤៤) |
| សមតុល្យថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០១៩ | (២៩០.៨០០) | (៥.១៩២.៥៩២) | (១០.០១៣.២៣០) | (១១០.៤៥០) | (១.៦៩៩.៤០៥) | (១៧.៣០៦.៤៧៧) |
| **តម្លៃយោងក្នុងបញ្ជីគណនេយ្យថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ (ដុល្លារអាមេរិក)** | ៣.៥៨៩.២០០ | ៣.៧៧៨.៧១៩ | ៧.២៧៩.៧៨៦ | ៦.៩៧០ | ១៧៧.០៣៦ | ១៤.៨៣១.៧១១ |
| **ពាន់រៀល (កំណត់សម្គាល់៤)** | ១៤.៦១៥.២២២ | ១៥.៣៨៦.៩៤៤ | ២៩.៦៤៣.២៨៩ | ២៨.៣៨២ | ៧២០.៨៩០ | ៦០.៣៩៤.៧២៧ |

| | ដីភតិសន្យារយៈពេលវែង<br>ដុល្លារអាមេរិក | សំណង់អាគារ<br>ដុល្លារអាមេរិក | រោងចក្រ និងគ្រឿងយន្ត<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារ និងកុំព្យូទ័រ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| បានធ្វើសវនកម្ម | | | | | | |
| តម្លៃដុលក្នុងបញ្ជីគណនេយ្យ | | | | | | |
| សមតុល្យនាថ្ងៃទី១ខែមករា ឆ្នាំ២០១៨ | ៣.៨៨០.០០០ | ៧.០៣២.៨៩០ | ១០.៥៥០.៨៧៧ | ៦៨.១០៩ | ៨៤៣.០៨៥ | ២២.៣៧៤.៩៦១ |
| ការដាក់បញ្ចូលវិញនូវទ្រព្យសកម្មដែលបានលុបចោល | - | ១.៩៣៨.៤២១ | ៣.៨៥៥.២៣៨ | ៤៩.៣១១ | ៩៦២.៧៦៧ | ៦.៨០៥.៧៣៧ |
| ការទិញបន្ថែម | - | - | ៨៦៩.៧៥៨ | - | ២២.៥៤២ | ៨៩២.៣០០ |
| សមតុល្យនាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៨ | ៣.៨៨០.០០០ | ៨.៩៧១.៣១១ | ១៥.២៧៥.៨៧៣ | ១១៧.៤២០ | ១.៨២៨.៣៩៤ | ៣០.០៧២.៩៩៨ |
| | | | | | | |
| រំលស់បង្គរ | | | | | | |
| សមតុល្យនាថ្ងៃទី១ខែមករា ឆ្នាំ២០១៨ | (២៣២.៨០០) | (២.៥៨១.៣២២) | (៤.៥៣០.១៩៦) | (៥៥.៩៧៦) | (៦៥១.៩៥៦) | (៨.០៥២.២៥០) |
| ការដាក់បញ្ចូលវិញនូវទ្រព្យសកម្មដែលបានលុបចោល | - | (១.៩៣៨.៤២១) | (៣.៨៥៥.២៣៨) | (៤៩.៣១១) | (៩៦២.៧៦៧) | (៦.៨០៥.៧៣៧) |
| រំលស់ប្រចាំឆ្នាំ | (៣៨.៨០០) | (៤៤៨.៥៦៦) | (១.០៣៨.០៨១) | (៣.៥៦១) | (៦០.២៣៨) | (១.៥៨៩.២៤៦) |
| សមតុល្យនាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៨ | (២៧១.៦០០) | (៤.៩៦៨.៣០៩) | (៩.៤២៣.៥១៥) | (១០៨.៨៤៨) | (១.៦៧៤.៩៦១) | (១៦.៤៤៧.២៣៣) |
| តម្លៃយោងក្នុងបញ្ជីគណនេយ្យនាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៨ (ដុល្លារអាមេរិក) | ៣.៦០៨.៤០០ | ៤.០០៣.០០២ | ៥.៨៥២.៣៥៨ | ៨.៥៧២ | ១៥៣.៤៣៣ | ១៣.៦២៥.៧៦៥ |
| ពាន់រៀល (កំណត់សម្គាល់ ៤) | ១៤.៥៩៥.៩៧៨ | ១៦.១៩២.១៤៣ | ២៣.៦៧២.៧៨៨ | ៣៤.៦៧៤ | ៦២០.៦៣៦ | ៥៥.១១៦.២១៩ |

## ៩ ទ្រព្យសកម្មអរូបិយ

| | កម្មវិធីកុំព្យូទ័រ | |
|---|---|---|
| | **មិនបានធ្វើសវនកម្ម ឆ្នាំ២០១៩ ដុល្លារអាមេរិក** | បានធ្វើសវនកម្ម ឆ្នាំ២០១៨ ដុល្លារអាមេរិក |
| **តម្លៃដុលក្នុងបញ្ជីគណនេយ្យ** | | |
| សមតុល្យថ្ងៃទី១ ខែមករា | **២២៤.៩៥៧** | ៨៧.៨៣៧ |
| ការដាក់បញ្ចូលវិញនូវទ្រព្យសកម្មដែលបានលុបចោល | - | ១៣៣.៣៨៤ |
| ការទិញបន្ថែម | - | ៣.៧៣៦ |
| សមតុល្យថ្ងៃទី៣០ ខែមិថុនា/ថ្ងៃទី៣១ ខែធ្នូ | **២២៤.៩៥៧** | ២២៤.៩៥៧ |
| **រំលស់** | | |
| សមតុល្យថ្ងៃទី១ ខែមករា | **(២១២.១៦៣)** | (៦៨.៩៨៩) |
| ការដាក់បញ្ចូលវិញនូវទ្រព្យសកម្មដែលបានលុបចោល | - | (១៣៣.៣៨៤) |
| រំលស់ក្នុងគ្រា | **(២.៥៩៧)** | (៩.៧៩០) |
| សមតុល្យថ្ងៃទី៣០ ខែមិថុនា/ថ្ងៃទី៣១ ខែធ្នូ | **(២១៤.៧៦០)** | (២១២.១៦៣) |
| **តម្លៃយោងក្នុងបញ្ជីគណនេយ្យថ្ងៃទី៣០ ខែមិថុនា/ថ្ងៃទី៣១ ខែធ្នូ (ដុល្លារអាមេរិក)** | **១០.១៩៧** | ១២.៧៩៤ |
| **ពាន់រៀល (កំណត់សម្គាល់៤)** | **៤១.៥២២** | ៥១.៧៥២ |

## ១០ សន្និធិ

| | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| វត្ថុធាតុដើម | **១៦.៤៩២.២២២** | **៦៧.១៥៦.៣២៩** | ៨.៧៨០.៩១៨ | ៣៥.៥១៨.៨១៣ |
| ផលិតផលមិនទាន់សម្រេច | **៧.៤០៤.៨៦៣** | **៣០.១៥២.៦០២** | ៦.៤៤៩.២០៤ | ២៦.០៨៧.០៣០ |
| ផលិតផលសម្រេច | **២.៨៥៩.៣១២** | **១១.៦៤៣.១១៨** | ១០.២១៩.៧៤៦ | ៤១.៣៣៨.៨៧៣ |
| | **២៦.៧៥៦.៣៩៧** | **១០៨.៩៥២.០៤៩** | ២៥.៤៤៩.៨៦៨ | ១០២.៩៤៤.៧១៦ |

## ១១ គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ

| | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **គណនីអតិថិជនពាណិជ្ជកម្ម** | | | | |
| ទឹកប្រាក់ជំពាក់ដោយក្រុមហ៊ុនសម្ព័ន្ធញាតិ (កំណត់សម្គាល់ ២៥) | **៤៧.៣៨៧.៨៨៣** | **១៩២.៩៦៣.៤៦០** | ៤៤.៨៩០.៥០០ | ១៨១.៥៨២.០៧៣ |
| **គណនីត្រូវទទួលផ្សេងៗ** | | | | |
| អាករលើតម្លៃបន្ថែមត្រូវទទួល | **១.១៩៧.២៨៧** | **៤.៨៧៥.៣៥២** | ៩៩៨.៧០១ | ៤.០៣៩.៧៤៥ |
| ចំណាយបង់មុន | **១.៩៦៩.៩៧០** | **៨.០២១.៧១៨** | ២.៩៤០.៤៦០ | ១១.៨៩៤.១៦១ |
| | **៣.១៦៧.២៥៧** | **១២.៨៩៧.០៧០** | ៣.៩៣៩.១៦១ | ១៥.៩៣៣.៩០៦ |
| | **៥០.៥៥៥.១៤០** | **២០៥.៨៦០.៥៣០** | ៤៨.៨២៩.៦៦១ | ១៩៧.៥១៥.៩៧៩ |

## ១២ សាច់ប្រាក់ និង សាច់ប្រាក់សមមូល

| | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| សាច់ប្រាក់ក្នុងដៃ | ៦៣.៨៦៧ | ២៦០.០៦៧ | ៤៩.២៥៤ | ១៩៩.២៣៣ |
| សាច់ប្រាក់នៅធនាគារ | ៥៩០.៩៩៣ | ២.៤០៦.៥២៣ | ៩៨៣.៦០៩ | ៣.៩៧៨.៦៩៨ |
| | ៦៥៤.៨៦០ | ២.៦៦៦.៥៩០ | ១.០៣២.៨៦៣ | ៤.១៧៧.៩៣១ |

## ១៣ ដើមទុន

| | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ដុល្លារអាមេរិក | ចំនួនភាគហ៊ុន | ដុល្លារអាមេរិក |
| ភាគហ៊ុនធម្មតា មានតម្លៃ០.២៥ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន | | | | |
| ភាគហ៊ុនដែលបានអនុញ្ញាតិអោយបោះផ្សាយ | ២០០.០០០.០០០ | ៥០.០០០.០០០ | ២០០.០០០.០០០ | ៥០.០០០.០០០ |
| បានបោះផ្សាយនិងបង់រួចៈ | ៤០.០០០.០០០ | ១០.០០០.០០០ | ៤០.០០០.០០០ | ១០.០០០.០០០ |
| ពាន់រៀល (កំណត់សម្គាល់៤) | | ៤០.៧២០.០០០ | | ៤០.៤៥០.០០០ |

## ១៤ បុព្វលាភភាគហ៊ុន

បុព្វលាភភាគហ៊ុនបង្ហាញពីសាច់ប្រាក់លើស ដែលទទួលបានដោយសារភាពខុសគ្នារវាងតម្លៃចារិករបស់ភាគហ៊ុន និងតម្លៃដាក់លក់របស់ភាគហ៊ុនចំនួន ១.១២៣.៨១០ ភាគហ៊ុនទៅអោយសាធារណៈជន សញ្ជាតិខ្មែរ និង ៦.៨៧៦.១៩០ភាគហ៊ុនទៅអោយវិនិយោគិនដែលបានជ្រើសរើស ដែលមានតម្លៃចារិក ០.២៥ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ហើយភាគហ៊ុននីមួយៗត្រូវបានលក់ក្នុងតម្លៃ ២.៤១ដុល្លារអាមេរិក នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។

## ១៥ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **រយៈពេលវែង** | | | | |
| គណនីត្រូវបង់ផ្សេងៗ | ១.៣៥០.០០០ | ៥.៤៩៧.២០០ | ១.៥៣០.០០០ | ៦.១៨៨.៨៥០ |
| **រយៈពេលខ្លី** | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | ២៦.៦៣៦ | ១០៨.៤៦០ | - | - |
| ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនសម្ព័ន្ធញាតិ (កំណត់សម្គាល់ ២៥) | ៩.២៩៣.៩១១ | ៣៧.៨៤៤.៨០៦ | ៧.៧០៧.៧៧៥ | ៣១.១៧៧.៩៥០ |
| បង្គរ | ១.៦២៤.៨១៣ | ៦.៦១៦.២៣៩ | ១.៣៥១.៥២៩ | ៥.៤៦៦.៩៣៥ |
| ពន្ធកាត់ទុកត្រូវបង់ | ៣៩៥.៥២៣ | ១.៦១០.៥៧០ | ៣៩៥.៥២៣ | ១.៥៩៩.៨៦១ |
| គណនីត្រូវបង់ផ្សេងៗ | ១.៦១៣.២៣០ | ៦.៥៦៩.០៧៥ | ១.៧៥០.៩៦៨ | ៧.០៨២.៦៩៥ |
| | ១២.៩៥៤.១១៣ | ៥២.៧៤៩.១៥០ | ១១.២០៥.៧៩៥ | ៤៥.៣២៧.៤៤១ |
| | ១៤.៣០៤.១១៣ | ៥៨.២៤៦.៣៥០ | ១២.៧៣៥.៧៩៥ | ៥១.៥១៦.២៩១ |

## ១៦ ប្រាក់កម្ចី

| | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| កម្ចីរយៈពេលខ្លី | | | | |
| ធនាគារពាណិជ្ជទីមួយ (កំណត់សម្គាល់ ១៦.១) | ៦.៤០០.០០០ | ២៦.០៦០.៨០០ | ៤.៤០០.០០០ | ១៧.៧៩៨.០០០ |
| ធនាគារតៃវ៉ាន់ខូអបភើរេធីវ (កំណត់សម្គាល់ ១៦.២) | ២.៤៦៧.៥៦០ | ១០.០៤៧.៩០៤ | ២.៦១៦.៩២៧ | ១០.៥៨៥.៤៧០ |
| | ៨.៨៦៧.៥៦០ | ៣៦.១០៨.៧០៤ | ៧.០១៦.៩២៧ | ២៨.៣៨៣.៤៧០ |

### ១៦.១. ប្រាក់កម្ចីជាមួយធនាគារពាណិជ្ជទីមួយ

យោងតាមកិច្ចសន្យាកម្ចីប្រាក់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ក្រុមហ៊ុនត្រូវបានផ្ដល់នូវកម្ចីរយៈពេលខ្លី ដែលមានចំនួនទឹកប្រាក់រហូតដល់៦.៤លានដុល្លារអាមេរិក (ឥណទានបង្វិល) ដោយធនាគារពាណិជ្ជទីមួយសាខាភ្នំពេញ។ រយៈពេលនៃការផ្ដល់ប្រាក់កម្ចីមានរយៈពេលមួយឆ្នាំ ហើយកាលបរិច្ឆេទកំណត់សងត្រូវបានបញ្ជាក់នៅក្នុងលិខិតធានានីមួយៗ។ អត្រាការប្រាក់ប្រចាំគឺ អត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR បូក ៤.២% ដែលធំជាងឬស្មើ ៥%។ ការប្រាក់ត្រូវបានគណនាតាមមូលដ្ឋាន ៣៦០ ថ្ងៃក្នុងមួយឆ្នាំនិងត្រូវបង់ប្រចាំខែ។

កម្ចីត្រូវបានបន្តចាប់ពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ សម្រាប់រយៈពេល ១ឆ្នាំ។ ការប្រាក់ប្រចាំឆ្នាំគឺ អត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR បូក ៣.៨%ដែលធំជាងឬស្មើ ៥%។

កម្ចីត្រូវបានបន្តឡើងវិញទៀតនាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨ សម្រាប់រយៈពេល ១ឆ្នាំ។ ការប្រាក់ប្រចាំឆ្នាំគឺ អត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR បូក ៣% ដែលធំជាងឬស្មើ ៥%។ អត្រាការប្រាក់ត្រូវបានទូទាត់ជាប្រចាំខែ និងគណនាលើមូលដ្ឋាន ៣៦០ថ្ងៃ ក្នុងមួយឆ្នាំ។

កម្ចីរយៈពេលខ្លី ត្រូវបានធានាដូចខាងក្រោម៖

- ក. លិខិតធានាដោយ លោក យ៉ាង សាវស៊ីន (Yang Shaw Shin) នាយកក្រុមប្រឹក្សាភិបាល
- ខ. កម្ចីដំបូងទៅលើដីធ្លី ដែលកាន់កាប់ដោយ លោក យ៉ាង សាវស៊ីន ជាមួយនឹងប័ណ្ណសម្គាល់ដីធ្លីលេខ ១២០៥០៥០១-០១១៩ ធ្វើឡើងថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ ទីតាំងស្ថិតនៅ ភូមិជម្ពូវ័ន្ត ត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និង
- គ. រាល់ទ្រព្យសកម្មបច្ចុប្បន្ន និងអនាគតរបស់ក្រុមហ៊ុន។

សម្រាប់រយៈពេល៦ខែ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនបានទូទាត់សងប្រាក់ដើមចំនួន ៥.៥៦០.០០០ ដុល្លារអាមេរិក (ឆ្នាំ២០១៨: ៨.០០០.០០០ដុល្លារអាមេរិក) និងដកប្រាក់កម្ចីពីធនាគារសរុបចំនួន ៧.៥៦០.០០០ ដុល្លារអាមេរិក (ឆ្នាំ២០១៨: ៨.៤០០.០០០ដុល្លារអាមេរិក)។

### ១៦.២. ប្រាក់កម្ចីជាមួយធនាគារតៃវ៉ាន់ខូអបភើរេធីវ

ក្រុមហ៊ុនបានចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារតៃវ៉ាន់ខូអបភើរេធីវ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលមានទឹកប្រាក់ចំនួន ៣លានដុល្លារអាមេរិកសម្រាប់រយៈពេល ៨៤ខែ រាប់គិតចាប់ពីថ្ងៃដកប្រាក់កម្ចីលើកដំបូង។
នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ និង ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុនបានដកប្រាក់កម្ចីចំនួន ២លានដុល្លារអាមេរិក និង ១លានដុល្លារអាមេរិក ជាបន្តបន្ទាប់។

សម្រាប់រយៈពេល៦ខែ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនបានទូទាត់សងប្រាក់ដើមចំនួន ១៤៩.៣៦៦ ដុល្លារអាមេរិក (ឆ្នាំ២០១៨: ៣៤៩.៩៧៥ដុល្លារអាមេរិក)។

អត្រាការប្រាក់ប្រចាំឆ្នាំគឺអត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR បូក ៣.៥៧៩៥%។ ការប្រាក់ត្រូវបង់ជារៀងរាល់ខែរាប់គិតចាប់ពីថ្ងៃដកប្រាក់កម្ចីលើកដំបូង។

កម្ចីរយៈពេលវែង ត្រូវបានធានាដូចខាងក្រោម៖

ក. លិខិតធានាដោយ លោក យ៉ាង សាវស៊ីន (Yang Shaw Shin) នាយកក្រុមប្រឹក្សាភិបាល

ខ. លំដាប់ទីមួយនៃហ៊ីប៉ូតែកលើអចលនវត្ថុដូចមានរៀបរាប់ខាងក្រោម (រួមមានទាំងដី និង សំណង់)

- លេខប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុ តក ០០៥៣១៥ (lxii ០០១៩/២១០៩០៩០៨-០០០១) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ មានទំហំដី ២២៦.៦៩៧ម² ដែលមានទីតាំងនៅ ភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជា។
- លេខប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុ តក ០០៥៣៦៦ (lxii ០០២០/២១០៩០៩០៨-០០០២) ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ មានទំហំដី ១៤.៨៧១ម² ដែលមានទីតាំងនៅ ភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជា។

## ១៧ ចំណូល

| | **មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ខែមិថុនាឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ការលក់ទំនិញ | **៤៣.៥៣២.៨៨៧** | **១៧៧.២៦៥.៩១៦** | ២៣.៧៩៩.៣៦០ | ៩៦.៧៦៨.១៩៨ |
| ការលក់បញ្ចុះតម្លៃ | - | - | (២៥.៤១១) | (១០៣.៣២១) |
| | **៤៣.៥៣២.៨៨៧** | **១៧៧.២៦៥.៩១៦** | ២៣.៧៧៣.៩៤៩ | ៩៦.៦៦៤.៨៧៧ |

| | មិនបានធ្វើសវនកម្ម<br>៦ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) | មិនបានធ្វើសវនកម្ម<br>៦ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) |
|---|---|---|---|---|
| ការលក់ទំនិញ | ៨០.៣១៣.៣៧៩ | ៣២៧.០៣៦.០៧៩ | ៤៦.២៤៤.៦៦៩ | ១៨៨.០៣០.៨២៤ |
| កាត់ ដេរ និងវេចខ្ចប់ | - | - | ៨៣៣.២៩០ | ៣.៣៨៨.១៥៧ |
| | ៨០.៣១៣.៣៧៩ | ៣២៧.០៣៦.០៧៩ | ៤៧.០៧៧.៩៥៩ | ១៩១.៤១៨.៩៨១ |
| ការលក់បញ្ចុះតម្លៃ | - | - | (២៥.៤១១) | (១០៣.៣២១) |
| | ៨០.៣១៣.៣៧៩ | ៣២៧.០៣៦.០៧៩ | ៤៧.០៥២.៥៤៨ | ១៩១.៣១៥.៦៦០ |

## ១៨ ថ្លៃដើម

| | មិនបានធ្វើសវនកម្ម<br>៣ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) | មិនបានធ្វើសវនកម្ម<br>៣ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) |
|---|---|---|---|---|
| វត្ថុធាតុដើម | ២៧.១៣៩.២៨៥ | ១១០.៥១១.១៧០ | ១៥.១៦៤.០៨៥ | ៦១.៦៥៧.១៧០ |
| ពលកម្មផ្ទាល់ | ៤.២៥៩.៤២២ | ១៧.៣៤៤.៣៦៧ | ៣.៨៣៥.៨៨៣ | ១៥.៥៩៦.៧០០ |
| ចំណាយផ្សេងៗ | ៩.៦៨១.៩៩៤ | ៣៩.៤២៥.០៧៧ | ៤.១៩០.១៥៧ | ១៧.០៣៧.១៧៨ |
| | ៤១.០៨០.៧០១ | ១៦៧.២៨០.៦១៤ | ២៣.១៩០.១២៥ | ៩៤.២៩១.០៤៨ |

| | មិនបានធ្វើសវនកម្ម<br>៦ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) | មិនបានធ្វើសវនកម្ម<br>៦ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) |
|---|---|---|---|---|
| វត្ថុធាតុដើម | ៥៣.៣៧៧.១១៧ | ២១៧.៣៥១.៦២០ | ៣១.០៥៧.០៣៩ | ១២៦.២៧៧.៩២១ |
| ពលកម្មផ្ទាល់ | ៧.៧៣៨.៥៥៤ | ៣១.៦៣៤.២៧២ | ៧.១៥២.៧៥៨ | ២៩.០៨៣.១១៤ |
| ចំណាយផ្សេងៗ | ១៣.៨៣៥.៩២៤ | ៥៦.៥០២.៧៦៣ | ៥.៦០៣.៣៩៤ | ២២.៧៨៣.៤០០ |
| | ៧៥.០៣១.៥៩៥ | ៣០៥.៥២៨.៦៥៥ | ៤៣.៨១៣.១៩១ | ១៧៨.១៤៤.៤៣៥ |

## ១៩ ចំណូលផ្សេងៗ

| | មិនបានធ្វើសវនកម្ម<br>៣ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) | មិនបានធ្វើសវនកម្ម<br>៣ខែ គិតត្រឹម<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨<br>ដុល្លារអាមេរិក | <br><br><br>ពាន់រៀល<br>(កំណត់សម្គាល់៤) |
|---|---|---|---|---|
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | ៦៩១ | ២.៨១៣ | ១.៧៤៧ | ៧.១០៣ |
| ផ្សេងៗ | ២.១៧៧ | ៨.៨៦៥ | ២៣.៨៧៧ | ៩៧.០៨៤ |
| | ២.៨៦៨ | ១១.៦៧៨ | ២៥.៦២៤ | ១០៤.១៨៧ |

| | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | **១.៦៦៤** | **៦.៧៧៦** | ២.៥១០ | ១០.២០៦ |
| ផ្សេងៗ | **១៦.៦៨០** | **៦៧.៩២១** | ៣៩.១៦០ | ១៥៩.២២៤ |
| | **១៨.៣៤៤** | **៧៤.៦៩៧** | ៤១.៦៧០ | ១៦៩.៤៣០ |

## ២០ ចំណាយរដ្ឋបាល

| | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ | **៤៨៣.២៨៦** | **១.៩៦៧.៨៤២** | ៣៥៣.៣៩២ | ១.៤៣៦.៨៩២ |
| ចំណាយបុគ្គលិក | **៤២០.១៦៩** | **១.៧១០.៩២៩** | ៣៥៤.០០៦ | ១.៤៣៩.៣៨៨ |
| ចំណាយលើសេវាកម្មវិជ្ជាជីវៈ | **៣០.៨៦១** | **១២៥.៦៦៧** | ២៩.៤១៧ | ១១៩.៦១០ |
| ចំណាយលើការរំលស់ | **២៤.៤១១** | **៩៩.៤០២** | ៣៧.៧៤០ | ១៥៣.៤៥១ |
| ចំណាយលើសម្ភារៈការិយាល័យ | **២៤.០១២** | **៩៧.៧៧៨** | ២០.៨៩៦ | ៨៤.៩៦៣ |
| ចំណាយលើការបរិច្ចាគ | **១០.០០០** | **៤០.៧២០** | - | - |
| ចំណាយលើការធ្វើដំណើរ | **៩.៧៥៧** | **៣៩.៧៣២** | ៧.៥១៩ | ៣០.៥៧២ |
| ចំណាយលើការជួសជុល និងថែរក្សា | **៩.១២១** | **៣៧.១៤២** | ១១.៨៤១ | ៤៨.១៤៦ |
| ចំណាយលើពន្ធ និងផ្សេងៗ | **៨.៥៦៨** | **៣៤.៨៩០** | ៥.៤២៤ | ២២.០៥៤ |
| ចំណាយប្រៃសណីយ៍ | **៦.៣៩៧** | **២៦.០៥០** | ៧.៤៦៤ | ៣០.៣៤៩ |
| ចំណាយធានារ៉ាប់រងទ្រព្យសម្បត្តិ | **៥.៨២៧** | **២៣.៧២៩** | ៩.៥៥៣ | ៣៨.៨៤២ |
| ចំណាយលើការជួលបរិក្ខារ | **៤.២៤៥** | **១៧.២៨៧** | ៣.៧១៥ | ១៥.១០៥ |
| ចំណាយលើការកំសាន្ត | **១.២៩៣** | **៥.២៦៦** | ១.៩២៥ | ៧.៨២៧ |
| ចំណាយលើទឹក និងភ្លើង | **១.០៥០** | **៤.២៧៧** | ៩០០ | ៣.៦៥៩ |
| ចំណាយផ្សេងៗ | **៦១.៩២២** | **២៥២.១៣១** | ៨៦.៩៨៦ | ៣៥៣.៦៨៥ |
| | **១.១០០.៩១៩** | **៤.៤៨២.៩៤២** | ៩៣០.៧៧៨ | ៣.៧៨៤.៥៤៣ |

| | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ | **៩៥១.៧៥៥** | **៣.៨៧៥.៥៤២** | ៧០៧.៦៥៧ | ២.៨៧៧.៣៣៣ |
| ចំណាយបុគ្គលិក | **៨៣២.៦០៧** | **៣.៣៩០.៣៧៦** | ៧៦៨.៨៣២ | ៣.១២៦.០៧១ |
| ចំណាយលើសម្ភារៈការិយាល័យ | **៥១.៨៧៣** | **២១១.២២៧** | ៣៩.៧៩៧ | ១៦១.៨១៥ |
| ចំណាយលើការរំលស់ | **៤៨.៥២៣** | **១៩៧.៥៨៦** | ៦២.១៩០ | ២៥២.៨២៤ |
| ចំណាយលើសេវាកម្មវិជ្ជាជីវៈ | **៤១.២២៣** | **១៦៧.៨៦០** | ៦២.៨៨៨ | ២៥៥.៧០៣ |
| ចំណាយលើពន្ធ និងផ្សេងៗ | **២១.០១៤** | **៨៥.៥៦៩** | ១៣.៧២១ | ៥៥.៧៩០ |
| ចំណាយលើការធ្វើដំណើរ | **១៧.២៥៥** | **៧០.២៦៨** | ១៥.២០០ | ៦១.៨០៣ |
| ចំណាយលើការជួសជុល និងថែរក្សា | **១៧.១៦២** | **៦៩.៨៨៤** | ២១.០៨៥ | ៨៥.៧៣២ |
| ចំណាយលើការបរិច្ចាក | **១០.០០០** | **៤០.៧២០** | - | - |
| ចំណាយប្រៃសណីយ៍ | **១៣.៥៨១** | **៥៥.៣០២** | ១៥.៤៧៩ | ៦២.៩៣៨ |
| ចំណាយធានារ៉ាប់រងទ្រព្យសម្បត្តិ | **១២.១០៣** | **៤៩.២៨៣** | ២០.១៣៤ | ៨១.៨៦៥ |
| ចំណាយលើការជួលបរិក្ខារ | **៨.២២០** | **៣៣.៤៧២** | ៧.៥១០ | ៣០.៥៣៦ |
| ចំណាយលើការកំសាន្ត | **៤.០៨០** | **១៦.៦១៤** | ៤.០៩៤ | ១៦.៦៤៦ |
| ចំណាយលើទឹក និងភ្លើង | **២.១០០** | **៨.៥៥១** | ១.៨០០ | ៧.៣១៩ |
| ចំណាយផ្សេងៗ | **១៤៨.៦៩១** | **៦០៥.៤៦៩** | ១៤៧.៩៣៨ | ៦០១.៥១៤ |
| | **២.១៨០.១៧៥** | **៨.៨៧៧.៦៧៣** | ១.៨៨៨.៣១៥ | ៧.៦៧៧.៨៨៩ |

## ២១ ចំណាយលើការដឹកជញ្ជូន

| | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ថ្លៃពន្ធគយ និងឯកសារ | **៧៥៧.៨៩៤** | **៣.០៨៦.១៤៥** | ៣៩៥.៦៦៧ | ១.៦០៨.៧៨២ |
| ថ្លៃដឹកជញ្ជូនចេញ | **២១២.៦១៦** | **៨៦៥.៧៧២** | ៦០.៩០២ | ២៤៧.៦២៨ |
| | **៩៧០.៥១០** | **៣.៩៥១.៩១៧** | ៤៥៦.៥៦៩ | ១.៨៥៦.៤១០ |

| | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ថ្លៃពន្ធគយ និងឯកសារ | **១.៤១០.៥៥១** | **៥.៧៤៣.៧២៣** | ៧២១.៧៧៧ | ២.៩៣៤.៧៤៥ |
| ថ្លៃដឹកជញ្ជូនចេញ | **១.០០៤.៣៨០** | **៤.០៨៩.៨៧៦** | ៧៩.៥៨៥ | ៣២៣.៥៩៣ |
| | **២.៤១៤.៩៣១** | **៩.៨៣៣.៥៩៩** | ៨០១.៣៦២ | ៣.២៥៨.៣៣៨ |

## ២២ ចំណាយហិរញ្ញប្បទាន

ចំនួននេះតំណាងអោយចំណាយការប្រាក់លើប្រាក់កម្ចី។

## ២៣ ពន្ធលើប្រាក់ចំណូល

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចក្នុងការបង់ពន្ធលើ ប្រាក់ចំណូលក្នុងអត្រា ២០% លើប្រាក់ចំណូលជាប់ពន្ធ ឬពន្ធអប្បបរមា ប្រសិនបើមួយណាមានតម្លៃច្រើនជាង។

ពន្ធអប្បបរមា គឺគណនាតាមអត្រា១%នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលគ្រប់ពន្ធទាំងអស់។ ពន្ធអប្បបរមាត្រូវបានពន្យាពេលបណ្តោះអាសន្ន រហូតដល់ចុងឆ្នាំ ២០២២ ដោយយោងតាមប្រកាសលេខ ១១៣០.ក.ស. ចុះ
ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន ត្រូវត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ ដោយសារតែការដាក់ពាក្យ និងការតាក់តែងច្បាប់ពន្ធមានច្រើនប្រភេទ ហើយងាយនឹងបកស្រាយខុស ដូច្នេះចំនួនដែលបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចនឹងមានការផ្លាស់ប្តូរនាពេលបន្ទាប់ នៅពេលដែលអាជ្ញាធរពន្ធដារបានធ្វើការត្រួតពិនិត្យ។

## ២៤ ចំណេញក្នុងមួយភាគហ៊ុន

| | **មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណេញ(ខាត)សម្រាប់បែងចែកដល់ភាគហ៊ុននិកធម្មតា | **២០៥.៥២០** | **៨៣៦.៨៧៨** | (៨៦៧.១៤៣) | (៣.៥២៥.៨០៣) |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់ គិតជាមធ្យម | **៤០.០០០.០០០** | **៤០.០០០.០០០** | ៤០.០០០.០០០ | ៤០.០០០.០០០ |
| ចំណេញ(ខាត)គោលក្នុងមួយភាគហ៊ុន | **០.០០៥** | **០.០២១** | (០.០២២) | (០.០៨៨) |
| ចំណេញ(ខាត)ថយចុះក្នុងមួយភាគហ៊ុន | **០.០០៥** | **០.០២១** | (០.០២២) | (០.០៨៨) |

| | **មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណេញសម្រាប់បែងចែកដល់ភាគហ៊ុននិកធម្មតា | **៣៧៧.៨៩២** | **១.៥៣៨.៧៧៦** | ៣១១.៧៦៦ | ១.២៦៧.៦៤០ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់ គិតជាមធ្យម | **៤០.០០០.០០០** | **៤០.០០០.០០០** | ៤០.០០០.០០០ | ៤០.០០០.០០០ |
| ចំណេញគោលក្នុងមួយភាគហ៊ុន | **០.០០៩** | **០.០៣៨** | ០.០០៨ | ០.០៣២ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន | **០.០០៩** | **០.០៣៨** | ០.០០៨ | ០.០៣២ |

ចំណេញថយចុះក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

គិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ ក្រុមហ៊ុនមិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុន ធម្មតានេះទេ។ ដូចនេះ ចំណេញថយចុះក្នុងមួយភាគហ៊ុន គឺមានតម្លៃស្មើនឹងចំណេញគោលក្នុងមួយភាគហ៊ុន។

## ២៥ សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ក្រុមហ៊ុនមានសមតុល្យជាមួយនឹងសម្ព័ន្ធញាតិដូចខាងក្រោម៖

| | ទំនាក់ទំនង | មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំនួនទឹកប្រាក់ជំពាក់ដោយ៖ | | | | | |
| Q MI Industrial Co.. Ltd | ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | **៤៧.៣៨៧.៨៨៣** | **១៩២.៩៦៣.៤៦០** | ៤៤.៨៩០.៥០០ | ១៨១.៥៨២.០៧៣ |
| ចំនួនទឹកប្រាក់ជំពាក់ទៅ៖ | | | | | |
| Quint Major Industrial Co.. Ltd. | ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | **៧.៩២៦.២៧១** | **៣២.២៧៥.៧៧៦** | ៦.៦៨៥.២៤៥ | ២៧.០៤១.៨១៦ |
| Q MI Industrial Co.. Ltd. | ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | **១.៣៦៧.៦៤០** | **៥.៥៦៩.០៣០** | ១.០២២.៥៣០ | ៤.១៣៦.១៣៤ |

សមតុល្យដែលនៅសល់ គឺមិនមានវត្ថុធានា មិនមានការប្រាក់ និងគ្មានរយៈពេលសងច្បាស់លាស់។

ក្រុមហ៊ុនមានប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | មិនបានធ្វើសវនកម្ម ៣ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| <u>ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ</u> | | | | |
| Q MI Industrial Co.. Ltd. | | | | |
| លក់ | **៤២.២៥១.៦២៦** | **១៧២.០៤៨.៦២០** | ២៣.៧៩៩.៣៦០ | ៩៦.៧៦៨.១៩៧ |
| ទិញវត្ថុធាតុដើម | **២៧.២៨២.២៤៩** | **១១១.០៩៣.៣១៨** | ២០.១៨៦.០៩១ | ៨២.០៧៦.៦៤៥ |
| ទិញគ្រឿងម៉ាស៊ីន | **១០៣.៧៩៣** | **៤២២.៦៤៧** | ៨២.៦៥៨ | ៣៣៦.០៨៨ |
| ប្រាក់ប្រមូលបាន | **១០.១២០.៦២៦** | **៤១.២១១.១៨៨** | ៥.៣១៥.៩៧១ | ២១.៦១៤.៧៣៧ |
| ការទូទាត់ជាសាច់ប្រាក់ | - | - | ១៤០.០០០ | ៥៦៩.២៤០ |
| ការលក់បញ្ចុះតម្លៃ | - | - | ២៥.៤១១ | ១០៣.៣២១ |
| កាត់កងជាមួយគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | **២៧.២៨២.២៤៩** | **១១១.០៩៣.៣១៨** | ២០.០៤៦.០៩១ | ៨១.៥០៧.៤០៥ |
| ការបង់ជំនួសសម្រាប់ក្រុមហ៊ុន | **១.៣៦៣.៦៨១** | **៥.៥៥២.៩០៩** | ៤៤១.៣៥៦ | ១.៧៩៤.៥៥៥ |
| ការបង់ជំនួសដោយក្រុមហ៊ុន | **៧៤.២៣៤** | **៣០២.២៨០** | ១២២.១៥៧ | ៤៩៦.៦៨៩ |
| បុរេប្រទានទៅក្រុមហ៊ុន | **៤៣០.០០០** | **១.៧៥០.៩៦០** | ២៧០.០០០ | ១.០៩៧.៨២០ |
| ការទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | **៤៣០.០០០** | **១.៧៥០.៩៦០** | ១៥០.០០០ | ៦០៩.៩០០ |
| Quint Major Industrial Co.. Ltd. | | | | |
| ថ្លៃដើមកិច្ចសន្យារង | **៤.៥៦៩.៤៥២** | **១៨.៦០៦.៨០៩** | ២៣៩.០៦៩ | ៩៧២.០៥៥ |
| ការទូទាត់សង | **៣.៥៨២.០០០** | **១៤.៥៨៥.៩០៤** | - | - |
| Success Index Group | | | | |
| កាត់កងជាមួយគណនីត្រូវបង់ផ្សេងៗ | - | - | ៧៨២.០០៤ | ៣.១៧៩.៦៣០ |
| ការទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | - | - | ៧៦៧.៤០៥ | ៣.១២០.២៦៨ |

| | **មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | មិនបានធ្វើសវនកម្ម ៦ខែ គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| <u>ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ</u> | | | | |
| Q MI Industrial Co.. Ltd. | | | | |
| លក់ | **៧៨.២៦៥.៦០៨** | **៣១៨.៦៩៧.៥៥៥** | ៤៦.២៤៤.៦៦៩ | ១៨៨.០៣០.៨២៦ |
| ទិញវត្ថុធាតុដើម | **៥១.៩៣៧.៩៧៨** | **២១១.៤៩១.៤៤៦** | ៣៥.៥៨៤.៣៤១ | ១៤៤.៦៨៥.៩៣១ |
| ទិញគ្រឿងម៉ាស៊ីន | **១.៩៨៩.៦៤៣** | **៨.១០១.៨២៧** | ៣៧០.០៥៨ | ១.៥០៤.៦៥៧ |
| ប្រាក់ប្រមូលបាន | **២៣.៨៣០.២៤៧** | **៩៧.០៣៦.៧៦៦** | ១៧.១០៥.៩៧១ | ៦៩.៥៥២.៨៧៧ |
| ការទូទាត់ជាសាច់ប្រាក់ | - | - | ៤៣២.៦១៤ | ១.៧៥៩.០១០ |
| ការលក់បញ្ចុះតម្លៃ | - | - | ២៥.៤១១ | ១០៣.៣២១ |
| កាត់កងជាមួយគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | **៥១.៩៣៧.៩៧៨** | **២១១.៤៩១.៤៤៦** | ៣៥.១៥១.៧២៧ | ១៤២.៩២៦.៩២០ |
| ការបង់ជំនួសសម្រាប់ក្រុមហ៊ុន | **១.៧៤៩.៩២៣** | **៧.១២៥.៦៨៧** | ៤៤២.១០៧ | ១.៧៩៧.៦០៩ |
| ការបង់ជំនួសដោយក្រុមហ៊ុន | **១០៥.៣៩០** | **៤២៩.១៤៦** | ៤៩៣.៧១៩ | ២.០០៧.៤៦៣ |
| កាត់កងជាមួយគណនីត្រូវបង់ផ្សេងៗ | - | - | ៣.៤៨៨ | ១៤.១៨២ |
| បុរេប្រទានទៅក្រុមហ៊ុន | **៦០០.០០០** | **២.៤៤៣.២០០** | ៣៧០.០០០ | ១.៥០៤.៤២០ |
| ការទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | **៦២០.០០០** | **២.៥២៤.៦៤០** | ៣០០.០០០ | ១.២១៩.៨០០ |
| Quint Major Industrial Co.. Ltd. | | | | |
| ថ្លៃដើមកិច្ចសន្យារង | **៥.៧៤៣.០២៦** | **២៣.៣៨៥.៦០២** | ២៣៩.០៦៩ | ៩៧២.០៥៥ |
| ការទូទាត់សង | **៤.៥០២.០០០** | **១៨.៣៣២.១៤៤** | - | - |
| Success Index Group | | | | |
| កម្រៃសេវាកម្ម (កាត់ដេរ និងវេចខ្ចប់) | - | - | ៨៣៣.២៩០ | ៣.៣៨៨.១៥៩ |
| កាត់កងជាមួយគណនីត្រូវបង់ផ្សេងៗ | - | - | ៧៨២.០០៤ | ៣.១៧៩.៦៣០ |
| ការទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | - | - | ១.៥៣៧.៤០៥ | ៦.២៥១.០៨៨ |

## ២៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុក្នុងប្រភេទនីមួយៗត្រូវបានបង្ហាញដូចខាងក្រោម៖

| | **មិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| **រំលស់ថ្លៃដើម** | | | | |
| គណនីពាណិជ្ជកម្ម និងគណនីទទួលផ្សេងទៀត (*) | **៤៧.៣៨៧.៨៨៣** | **១៩២.៩៦៣.៤៦០** | ៤៤.៨៩០.៥០០ | ១៨១.៥៨២.០៧៣ |
| សមតុល្យសាច់ប្រាក់ និងសាច់ប្រាក់សមមូល | **៦៥៤.៨៦០** | **២.៦៦៦.៥៩០** | ១.០៣២.៨៦៣ | ៤.១៧៧.៩៣១ |
| | **៤៨.០៤២.៧៤៣** | **១៩៥.៦៣០.០៥០** | ៤៥.៩២៣.៣៦៣ | ១៨៥.៧៦០.០០៤ |

(*) មិនរាប់បញ្ចូលការបង់ប្រាក់មុន និងអាករលើតម្លៃបន្ថែមត្រូវទទួល

| | **មិនបានធ្វើសវនកម្ម** | | បានធ្វើសវនកម្ម | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| **រំលស់ថ្លៃដើម** | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ (*) | **១៣.៩០៨.៥៩០** | **៥៦.៦៣៥.៧៨០** | ១២.៣៤០.២៧២ | ៤៩.៥១៦.៤០០ |
| ប្រាក់កម្ចី | **៨.៨៦៧.៥៦០** | **៣៦.១០៨.៧០៤** | ៧.០១៦.៩២៧ | ២៨.៣៨៣.៤៧០ |
| | **២២.៧៧៦.១៥០** | **៩២.៧៤៤.៤៨៤** | ១៩.៣៥៧.១៩៩ | ៧៨.២៩៩.៨៧០ |

(*) មិនរាប់បញ្ចូលបំណុលលើពន្ធកាត់ទុក

## ២៧ កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគឺ ដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុននិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អ ដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ហេតុនេះគណៈគ្រប់គ្រង បង្កើតគោលការណ៍លម្អិតដូចជា កម្រិតសិទ្ធិអំណាច ទំនួលខុសត្រូវក្នុងការត្រួតពិនិត្យ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

### ២៧.១ ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍ក្រុមហ៊ុនត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថាក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែលក្រុមហ៊ុនងាយរងផលប៉ះពាល់ គឺតាមរយៈគណនីពាណិជ្ជកម្មត្រូវទទួល។ អាយុកាលឥណទានរបស់ក្រុមហ៊ុនមានរយៈពេល ៣ខែ ហើយក្រុមហ៊ុនព្យាយាមធ្វើការគ្រប់គ្រងយ៉ាងជិតដល់លើគណនីត្រូវទទួលដែលមិនទាន់ប្រមូលដើម្បីកាត់បន្ថយហានិភ័យឥណទានអោយទាបបំផុត។ សមតុល្យដែលហួសកាលកំណត់ត្រូវពិនិត្យឡើងវិញអោយបានទៀងទាត់ដោយគណៈគ្រប់គ្រង។

### ២៧.២ ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ ក្រុមហ៊ុនទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែលក្រុមហ៊ុននឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

ក្រុមហ៊ុនគ្រប់គ្រងយ៉ាងសកម្មលើរយៈកាលកំណត់របស់បំណុលចាស់ៗ លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិ ដើម្បីធានាអោយបាននូវរាល់តម្រូវការប្រតិបត្តិការវិនិយោគនិងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ក្រុមហ៊ុនធ្វើការរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលអោយបានគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ក្រុមហ៊ុន សម្រាប់រយៈពេល១២ខែបន្ទាប់។

### ២៧.៣ ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនអាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមមុខរបស់ក្រុមហ៊ុនទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងនឹងកម្ចី។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើបំណុលទីផ្សារ ហើយសំខាន់ជាងនេះទៀតគឺ រក្សាអោយបានការលាយឡំគ្នារបស់អត្រាថេរ និងអត្រាអថេររបស់កម្ចី ដោយប្រុងប្រយ័ត្ន។ ក្រុមហ៊ុនពុំបានប្រើប្រាស់ ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (Derivative Financial Instrument) ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

## ២៨ ពន្ធយថាហេតុ

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជាមានសភាពថ្មី ហើយពន្ធត្រូវបានបែងចែកជាច្រើនប្រភេទ និងបទបញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាធម្មតាពុំមានភាពច្បាស់លាស់ មានភាពផ្ទុយគ្នា និងជាកម្មវត្ថុនៃការបកស្រាយ។ ជាញឹកញាប់ការបកស្រាយខុសគ្នាៗជាច្រើន កើតមានឡើងក្នុងចំនោមអជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការផាកពិន័យធ្ងន់ធ្ងរ និងពិន័យលើការប្រាក់។ កត្តាទាំងនេះហើយ ដែលអាចធ្វើអោយមានហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ ថ្នាក់ដឹកនាំមានការជឿជាក់ថា ខ្លួនបានធ្វើសំវិធានធនបំណុលពន្ធគ្រប់គ្រាន់ ដោយផ្អែកលើការបកស្រាយបទបញ្ញត្តិបច្ចុប្បន្នរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពន្ធដារដែលជាប់ពាក់ព័ន្ធអាចមានការបកស្រាយខុសៗគ្នាហើយអាចធ្វើអោយមានផលប៉ះពាល់ជាសារវន្ត។

## ២៩ កិច្ចសន្យាមូលធន

នៅចុងត្រីមាសនៃការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រុមហ៊ុនបានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនសម្រាប់ការទិញការិយាល័យស្រាវជ្រាវ ពីក្រុមហ៊ុន TACC (C.R) Ltd មានចំនួនទឹកប្រាក់ ៥.៩១៣.០៤៤ដុល្លារអាមេរិក (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨: ៥.១៣៣.៧៧៨ដុល្លារអាមេរិក)។

## ៣០ ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

មិនមានព្រឹត្តិការណ៍កែសម្រួល និងព្រឹត្តិការណ៍មិនកែសម្រួលសំខាន់ៗណាមួយ បានកើតឡើងចន្លោះ
ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ និងថ្ងៃដែលបានអនុម័តអោយប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នទេ។

## ៣១ ការអនុញ្ញាតនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន

របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នសម្រាប់ត្រីមាស និងរយៈពេល៦ខែ ចុងការិយបរិច្ឆេទ
ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ត្រូវបានអនុម័តដោយនាយកក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។